ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
..............

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨៨៦ / ១៤.១១.២០០៦
សាលដីកា
លេខ: ១៤ ក្រ.III.ស / ០៣.១០.២០១៤

តាងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted]

<u>ក្រឡាបញ្ជី</u>

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងទាស់ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៨៨៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៦ រវាង ៖

១. ជនជាប់ចោទឈ្មោះ [redacted] សើ ហៅ ង៉ា ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករចូកខ្សាច់ ទីកន្លែងកំណើត [redacted] ទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន, ចាប់ខ្លួនថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៦ ។

២. ជនជាប់ចោទឈ្មោះ [redacted] វុធ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករចូកខ្សាច់ ទីកន្លែងកំណើត [redacted] ទីលំនៅមុនពេលចាប់ខ្លួន ៩

[redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៦។

៣. ជនជាប់ចោទឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករចូកខ្សាច់ ទីកន្លែងកំណើត [redacted] ទីលំនៅមុនពេលចាប់ខ្លួន ភូមិ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន, ចាប់ខ្លួនថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦

៤. ជនជាប់ចោទឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករចូកខ្សាច់ ទីកន្លែងកំណើត [redacted] ទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន, ចាប់ខ្លួនថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ឃុំខ្លួនថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៦។

ជនជាប់ចោទទាំងបួននាក់មានលោក [redacted] ម៉ាច ជាមេធាវីការពារ។

<u>ជាប់ចោទពីបទៈ</u> ឃាតកម្មដោយចេតនា ប្រព្រឹត្តនៅ ភូមិតាវៀន ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរជួសជុលម៉ូតូ ទីលំនៅសព្វថ្ងៃភូមិតាវៀន ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប។

## <u>ដំណើររឿងមានដូចតទៅ ៖</u>

តាមពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] សុគុល ជាប្រពន្ធជនរងគ្រោះឈ្មោះ [redacted] សុម៉េង ប្តឹងថាៈ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ម៉ោងប្រហែល៩យប់ មានរថយន្តមួយចាំងកន្លះដឹកមនុស្សពី ៤-១០នាក់ ដល់មុខផ្ទះខ្លួនប្រដាប់ដោយដំបងដែក, ឈើគ្រប់ដៃ បានវាយប្តីខ្លួន និងបងប្អូនខ្លួន ដេញវាយគ្នារត់ចូលក្នុងផ្ទះខ្លួនៗ ក៏យរត់ទៅមុខឃើញមនុស្សម្នាក់ខ្លួនស្គាល់មុខ និងផ្ទះច្បាស់, មិនស្គាល់ឈ្មោះម្នាក់ឈរបញ្ជាឲ្យវាយប្តីខ្លួនថាជាមេក្មេង មានរឿងអីចាំអញដោះស្រាយ។ សុំផ្តន្ទាទោសជនល្មើស និងសុំទារសំណងជម្ងឺចិត្ត ចំនួន ៤០.០០០$ (បួនម៉ឺនដុល្លារអាមេរិក)។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៦៧«ឃ» ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូង ខេត្តសៀមរាប-ឧត្តរមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១. ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ ៖

ក. ឈ្មោះ [redacted] សេរី ហៅ ង៉ា ដាក់គុកកំណត់១៥ឆ្នាំ(ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន,

ខ. ឈ្មោះ [redacted] វុធ ដាក់គុកកំណត់១៥ឆ្នាំ(ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន,

គ. ឈ្មោះ [redacted] ប្រុស ដាក់គុកកំណត់១៥ឆ្នាំ(ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន,

ឃ. ឈ្មោះ [redacted] ហេង ដាក់គុកកំណត់១៥ឆ្នាំ(ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន,

ង. ឈ្មោះ [redacted] លៀប ដាក់គុកកំណត់១៨ឆ្នាំ(ដប់ប្រាំបីឆ្នាំ) គិតពីថ្ងៃឃុំខ្លួន,

ច. ឈ្មោះ [redacted] នីន ដាក់គុកកំណត់១៧ឆ្នាំ(ដប់ប្រាំពីរឆ្នាំ) គិតពីថ្ងៃឃុំខ្លួន,

ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅ ភូមិតាវៀន ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២,

២. បង្គាប់ឲ្យឈ្មោះ [redacted] សេរី, ឈ្មោះ [redacted] វុធ, ឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] លៀប, ឈ្មោះ [redacted] នីន រួបរួមគ្នាសងថ្លៃថ្នាំព្យាបាល និងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១៦លានរៀល (ដប់ប្រាំមួយលានរៀល) ទៅឈ្មោះ [redacted] សុម៉េង ជាតំណាងឲ្យជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណី, សុំលើសពីនេះលើកចោល។ ក្នុងករណីគ្មានប្រាក់សងជនទទួលទោស ត្រូវដាក់គុកបង្ខំលើរូបកាយ តាមមាត្រា៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំលើរូបកាយ រឿងព្រហ្មទណ្ឌម្នាក់ៗ គឺ២ឆ្នាំ។

៣. វត្ថុតាងមាន: បំពង់ទីបចំនួន៣, ដែកស្បែង១, កាំបិតខ្មែរ១, ដំបងឈើ៣ ត្រូវរឹបអូស ហើយបំផ្លាញចោល។

៤. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សេរី, ឈ្មោះ [redacted] វុធ, ឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] ហេង និងដើមបណ្ដឹងរដ្ឋប្បវេណី, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] លៀប, ឈ្មោះ [redacted] នីន,

ទុកសិទ្ធិប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្ដឹងឧទ្ធរណ៍ លេខ ៩២ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សេរី, ឈ្មោះ [redacted] វុធ, ឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] ហេង ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៧ «ឃ» ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូង ខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។ល

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១៣២(ខ) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥២ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សេរី, ឈ្មោះ [redacted] វុធ, ឈ្មោះ [redacted] ប្រុស និងឈ្មោះ [redacted] ហេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៧ «ឃ» ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ទុកជាបានការ តែលុបវិធានអនុវត្តដាក់គុកបង្គំរូបកាយចេញពីការប្រកាសនៃសាលក្រម។

៣. បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទជាបន្តទៀត។

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ មេធាវីការពារដើមបណ្តឹង និងដើមបណ្តឹងរដ្ឋប្បវេណី,

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

បានឃើញបណ្តឹងទាស់លេខ ០១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] សេរី, ឈ្មោះ [redacted] វុធ, ឈ្មោះ [redacted] ប្រុស និងឈ្មោះ [redacted] ហេង ប្តឹងឧទ្ធរណ៍នឹងសាលដីកាព្រហ្មទណ្ឌលេខ ១៣២ (ខ) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## <u>នាពេលសវនាការ</u>

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជី អានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយនៅសវនាការសាលាឧទ្ធរណ៍។

ជនជាប់ចោទឈ្មោះ [redacted] សេរី, ឈ្មោះ [redacted] វុធ, ឈ្មោះ [redacted] ប្រុស និងឈ្មោះ [redacted] ហេង ឆ្លើយសារភាពទទួលស្គាល់នូវចម្លើយរៀងៗខ្លួន ដែលបានឆ្លើយនៅសមត្ថកិច្ចនគរបាល និងនៅតុលាការ បានបញ្ជាក់ថា នៅពេលនោះ ពួកខ្លួនបានទៅរួមសកម្មភាពមែន, ទៅដោយសារឈ្មោះ [redacted] ហាំងសេង ជាចៅកែហៅទៅជួយរកប្អូនគាត់, លុះទៅដល់ ក៏ស្រាប់តែមានជម្លោះវាយគ្នា ប្រទូស្តប្រទ្រាសគ្នា តបតគ្នាទៅវិញទៅមក ហើយភាគីម្ខាងនោះ ក៏បានទទួលរងគ្រោះបណ្តាលឲ្យស្លាប់ម្នាក់

និងរបួសម្នាក់ ដោយការវាយគ្នាទៅវិញទៅមក, ពួកខ្លួនទៅបានវាយតប់គ្នា មិនមែនមានបំណង សម្លាប់ជនរងគ្រោះនោះទេ។ សំណូមពរ សុំបន្ធូរបន្ថយទោស ដល់ពួកខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីស្តាប់ការសួរដេញដោល ឃើញថា ជនជាប់ចោទទាំងបួននាក់ ពិតជាបានធ្វើសកម្មភាព ដូចការចោទប្រកាន់របស់អយ្យការសាលាដំបូងពិតមែន សូមសភាព្រហ្មទណ្ឌពិចារណា និងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

នៅក្នុងរឿងនេះ មានករណីទំនាស់២ ទី១នោះគឺទំនាស់រវាង [redacted] ហាំងសេង ឈ្មោះ [redacted] នៀប ឈ្មោះ [redacted] ហឿន មួយក្រុមទៅ បានវាយគ្នា, មួយសារក្រោយមកបាត់ក្រុមគ្រួសារខ្លួនម្នាក់ ក៏ក្រុម [redacted] ហាំងសេង ដែលមានឈ្មោះ [redacted] នៀប មកហៅឲ្យកូនក្តីខ្លួនទាំងបួននាក់ ដែលសុទ្ធតែជាកម្មករ រស់ក្រោមការបង្គាប់បញ្ជា និងស៊ីប្រាក់ខែគេ ឲ្យទៅជួយរកបងប្អូន អញ្ចឹងក្នុងនាមជាកម្មករ ថៅកែប្រើ មិនហ៊ានប្រកែកទេ ត្រូវតែទៅ តែទៅនេះមិនមែនថាទៅដើម្បីសំលាប់ភាគីម្ខាងទៀតទេ គឺទៅក្នុងការជួយរកមនុស្ស ហើយថៅកែក៏បានទៅជាមួយ។ តាមការអះអាងរបស់គាត់នោះ គឺថា នៅពេលទៅដល់ គឺមានកើតហេតុវាយគ្នារួចទៅហើយ នៅក្នុងអង្គហេតុក៏មានបញ្ជាក់ថា នៅពេលចេញទៅ គឺខាងឈ្មោះ [redacted] ហាំងសេង ជិះម៉ូតូ ចំណែកកូនក្តីខ្លួនទៅដើរ អញ្ចឹងគាត់ទៅតាមក្រោយ ហើយក៏មានការវាយតប់គ្នា នៅពេលនោះក៏មានសមត្ថកិច្ចនៅកន្លែងកើតហេតុ ហើយបើតាមសមត្ថកិច្ចបញ្ជាក់ថា ការវាយគ្នានេះទៅដល់វាយគ្នាភ្លាម ខាងនោះក៏មានកំលាំង៧-៨នាក់ មានកាំបិត មានខ្សែវ៉ាត់ ទប់ទល់។ តាមចម្លើយរបស់សមត្ថកិច្ចឈ្មោះ [redacted] វ៉ានឌី ក៏ដូចជាសមត្ថកិច្ចឈ្មោះ [redacted] ឡី គឺថា ពីរក្រុមនេះសុទ្ធតែប្រើអាវុធគ្រប់ដៃវាយគ្នាពេញហ្នឹង។ ដូចនេះឃើញថា ការផ្តន្ទាទោសភាគីប៉ុន្មាននាក់នេះក៏មិនមានភាពយុត្តិធម៌ដែរ ពីព្រោះជាការមួយប្រើហិង្សាទៅវិញទៅមកកាប់គ្នាពេញក្រុង វាជាចេតនាមួយក្នុងការប្រព្រឹត្តបទល្មើសដូចគ្នា ប៉ុន្តែដោយសារភាគីម្ខាងមានរបួស ខាងនេះអត់របួស ខាងនោះមានអ្នកស្លាប់ ក៏សួរថាបន្ទុកនៃការចោទប្រកាន់មកខាងនេះ ក៏មិនមានភាពយុត្តិធម៌ដែរ ហើយកូនក្តីខ្លួនគាត់បានទៅជាមួយថៅកែ ដល់កន្លែងកើតហេតុ ពេលគេវាយគ្នារួចហើយ។ ជាក់ស្តែងសមត្ថកិច្ចក៏បានអះអាងថា នៅពេលវាយគ្នាហើយនោះ គាត់ឃើញភាគីម្ខាងរត់មក ហើយស្រែកឲ្យគាត់ជួយ ហើយគាត់ឃាត់ឲ្យឈរ១ដុំ ហើយកូនក្តីខ្លួនគាត់បានអះអាងថាសមត្ថកិច្ចឃាត់ឲ្យឈរ ហើយក៏បានហៅគាត់ឲ្យឡើងឡានទៅ នេះបើសិនជាកូនក្តីខ្លួនគាត់ជាជនដៃដល់ ជាអ្នកសំលាប់ មានចេតនាទៅសំលាប់ គាត់រត់ ៤

គេចខ្លួនបាត់ទៅហើយ ប៉ុន្តែគាត់ឈរចាំស្មៀមឲ្យសមត្ថកិច្ចប្រមូលឡើងឡានទៅឆ្លើយបំភ្លឺ។ ដូចនេះ សុំឲ្យលោកប្រធានក្រុមប្រឹក្សាពិនិត្យទៅលើជនដៃដល់ រវាងកូនក្តីដែលជាកម្មករគេ ឥឡូវនេះគាត់ជាប់បាន៧-៨ឆ្នាំ ហើយ សូមឲ្យក្រុមប្រឹក្សាជួយពិនិត្យលើចំណុចនេះ ហើយផ្តល់ឱកាសឲ្យគាត់ដោយសុំផ្តល់នូវស្ថានសម្រាលទោសតាមមាត្រា ៩៣, ៩៤ នៃក្រមព្រហ្មទណ្ឌ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ
## យល់ឃើញថាៈ

១. បណ្តឹងទាស់លេខ ០១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] សេរី និងឈ្មោះ [redacted] វុធ ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់តាមមាត្រា ៤១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. ជនជាប់ចោទទាំង៤នាក់ បានឆ្លើយសារភាពទទួលស្គាល់នូវចម្លើយរៀងៗខ្លួន ដែលបានឆ្លើយនៅសមត្ថកិច្ចនគរបាល និងនៅតុលាការ និងបានបញ្ជាក់ថា នៅពេលនោះ ពួកខ្លួនបានទៅរួមសកម្មភាពមែន ដោយសារឈ្មោះ [redacted] ហាំងសេង ជាថៅកែ ហៅទៅជួយរកប្អូនគាត់, លុះទៅដល់ក៏ស្រាប់តែមានជម្លោះវាយគ្នា ប្រទូស្តប្រទាសគ្នា តបតគ្នាទៅវិញទៅមក ហើយភាគីម្ខាងនោះក៏បានទទួលរងគ្រោះបណ្តាលឲ្យស្លាប់ម្នាក់ និងរបួសម្នាក់ ដោយការវាយគ្នាទៅវិញទៅមក,

ពួកខ្លួនទៅ បានវាយតប់គ្នា មិនមែនមានបំណងសម្លាប់ជនរងគ្រោះនោះទេ។

៣. ក្រុមជនជាប់ចោទពិតជាបានចូលរួមសកម្មភាពវាយគ្នាមែន តែដោយថៅកែរបស់ពួកខ្លួនហៅឲ្យទៅជួយរកប្អូនគាត់, ដូច្នេះ ការចូលរួមរបស់ក្រុមជនជាប់ចោទនេះ គឺដោយ ដោយរោយតាមថៅកែរបស់ពួកគេ ហើយលកើតការវាយប្រឆាំងគ្នាភ្លាមៗ ពុំមែនបានរៀបចំគម្រោងពួនស្ទាក់ដើម្បីធ្វើឃាតឡើយ គឺប្រព្រឹត្តក្នុងសភាពភ្លាមៗ ដោយចេតនា គ្មានការគិតទុកជាមុនឡើយ។

៤. មានកស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] សេរី និងឈ្មោះ [redacted] វុធ ពីបទ ឃាតកម្មដោយចេតនា ប្រព្រឹត្តនៅ ភូមិតាវៀន ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដូច្នេះ គួរកែប្រែបទចោទ និងសម្រេចឡើងវិញ ឲ្យបានត្រឹមត្រូវតាមបទចោទ ដែលបានកែប្រែ។

៥. ចំណុចទី២ នៃសាលដីកាព្រហ្មទណ្ឌលេខ ១៣២ (ខ) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ មានការខ្វះខាត គួរកែប្រែឡើងវិញ ដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងទាស់លេខ ០១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ហេង, ឈ្មោះ [redacted] ប្រុស, ឈ្មោះ [redacted] សេរី និងឈ្មោះ [redacted] វុធ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់។

២. កែប្រែចំណុចទី២ នៃសាលដីកាព្រហ្មទណ្ឌ ១៣២ (ខ) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ជាៈ

តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៧ «ឃ» ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ទុកជាបានការ លើកលែងតែបទចោទប្រកាន់ និងការផ្តន្ទាទោសលើជនជាប់ចោទនៅក្នុងចំណុចទី១ ក, ខ, គ, ឃ ត្រូវៈ

ក. កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] សេរី, ឈ្មោះ [redacted] វុធ, ឈ្មោះ [redacted] ប្រុស និងឈ្មោះ [redacted] ហេង ពីបទ ឃាតកម្មគិតទុកជាមុន ទៅជាបទ ឃាតកម្មដោយចេតនា ប្រព្រឹត្តនៅ ភូមិតាវៀន ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ខ. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សេរី ហៅ ង៉ា, ឈ្មោះ [redacted] វុធ, ឈ្មោះ [redacted] ប្រុស និងឈ្មោះ [redacted] ហេង ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ១០ (ដប់) ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទ ឃាតកម្មដោយចេតនា ប្រព្រឹត្តនៅ ភូមិតាវៀន ឃុំសាលាកំរើក ស្រុកសៀមរាប

ខេត្តសៀមរាប កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ក្រៅពីនេះ រក្សាទុកនៅជាបានការដដែល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទទាំង៤នាក់ និងមេធាវីការពារជនជាប់ចោទ,

បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះតទៅ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

.............................................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]